ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Royaume du Cambodge
Nation Religion Roi

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 24 / 04 / 2008
ម៉ោង (Time/Heure): 16 : 00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Chambres Extraordinaires au sein des Tribunaux Cambodgiens

ការិយាល័យសហចៅក្រមស៊ើបអង្កេត
Office of the Co-Investigating Judges
Bureau des Co-juges d'instruction

សំណុំរឿងព្រហ្មទណ្ឌ
Criminal Case File /Dossier pénal
លេខ/No: 002/14-08-2006

លេខស៊ើបសួរ/Investigation/Instruction
លេខ/No: 001/18-07-2007-ECCC-OCIJ

# កំណត់ហេតុនៃការចុះធ្វើការស៊ើបអង្កេតដល់កន្លែងកើតហេតុ
# Report on reconstruction
# Procès verbal de transport sur les lieux

ឆ្នាំពីរពាន់ប្រាំបី ខែកុម្ភៈ ថ្ងៃទីម្ភៃប្រាំពីរ នៅវេលាម៉ោង ប្រាំបី គត់

បានឃើញការបើកការស៊ើបសួរលើឈ្មោះ **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច** ត្រូវបានដាក់អោយស្ថិតក្រោមការពិនិត្យចំពោះបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការរំលោភបំពានធ្ងន់ធ្ងរលើសន្ធិសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ១៩៤៩ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៥ មាត្រា ៦ មាត្រា ២៩ (ថ្មី) និងមាត្រា ៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ២០០៤។

បានឃើញវិធាន ៥៥(៨) នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ

បានឃើញដីកាចុះដល់ទីកន្លែង ចុះថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ ២០០៨

យើង **យូ ប៊ុនឡេង** និង **Marcel Lemonde** សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ដោយមានវត្តមានលោក **ហាម ហ៊ើល** និងលោក **លី ច័ន្ទតុលា** ជាក្រឡាបញ្ជី



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C

និងលោក តាន់ ប៊ាងដាវ័ណ្ណ លោក អ៊ុច ចាន់ណូរ៉ា និងលោក ជីន សាំវិបុល អ្នកបកប្រែនៃអង្គជំនុំ-ជម្រះវិសាមញ្ញ ដែលបានស្បថរួចហើយ។

យើងធ្វើដំណើរមកដល់បរិវេណនៃសារមន្ទីរទួលស្លែង រាជធានីភ្នំពេញ [រូបថត ល. ១]

នៅទីនោះ យើងឃើញមាន៖

- លោកស្រី ជា លាង និងលោក Robert Petit សហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញ
- **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច** [រូបថត ល. ២] និងមេធាវីរបស់ខ្លួនលោក **ការ សាវុត្ថ** និងលោក François Roux
- **ជុំ ម៉ី** [រូបថត ល. ៣] ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីរបស់ខ្លួន លោក **ហុង គីម សួន**
- **ប៊ូ ម៉េង** [រូបថត ល. ៤] ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីរបស់ខ្លួន លោក **យុង ផានិត**
- សាក្សី **វ៉ាន់ ណាត** [រូបថត ល. ៥], **ម៉ម ណៃ** [រូបថត ល. ៦], **សួស ធី** [រូបថត ល. ៧], **ហ៊ីម ហ៊ុយ** [រូបថត ល. ៨], **សោម ម៉េត** [រូបថត ល. ៩], **ប្រាក់ ខន** [រូបថត ល. ១០], **គង់ ផៃ** [រូបថត ល. ១១]។

អ្នកជំនាញ Zoran LESIC ដែលត្រូវបានចាត់តាំងដោយដីកាចុះថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ ២០០៨ ក៏មានវត្តមាននៅទីនោះផងដែរ ដើម្បីរៀបចំរបាយការណ៍របស់ខ្លួន ហើយបានថតរូបដែលមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធនៃកំណត់នេះ (ឧបសម្ព័ន្ធ ១)។

១) *ការហៅឈ្មោះអ្នកដែលមានវត្តមាន* [រូបថត ល. ១២], ជនត្រូវចោទប្រកាសថាស្គាល់ **វ៉ាន់ ណាត**, **ប៊ូ ម៉េង**, **ជុំ ម៉ី**, **ម៉ម ណៃ**, **សួស ធី** និង **ហ៊ីម ហ៊ុយ**។

**ហ៊ីម ហ៊ុយ** ប្រកាសថាស្គាល់អ្នកទាំងអស់ដែលមានវត្តមាន ទាំងជនរងគ្រោះ និងសាក្សី។

សាក្សី **សួស ធី** ប្រកាសថាស្គាល់ **ឌុច**, **វ៉ាន់ ណាត**, **ម៉ម ណៃ**, **ហ៊ីម ហ៊ុយ**, **សោម ម៉េត** និង**ប្រាក់ ខន**។

សាក្សី **គង់ ផៃ** ប្រកាសថាស្គាល់ **ឌុច**, **ម៉ម ណៃ** និង **ហ៊ីម ហ៊ុយ**។

**ម៉ម ណៃ** ប្រកាសថាស្គាល់ **ឌុច** និង**ហ៊ីម ហ៊ុយ** ប៉ុន្តែថាមិនស្គាល់អ្នកផ្សេងទៀតទេ។

**សោម ម៉េត** ប្រកាសថាស្គាល់ **ឌុច**, **ហ៊ីម ហ៊ុយ**, **សួស ធី**, **ម៉ម ណៃ** និង**ប្រាក់ ខន**។

ប្រាក់ ខន ប្រកាសថាស្គាល់ ឌុច, ជុំ ម៉ី, ម៉ម ណៃ, សួស ធី, សោម ម៉េត, ហ៊ឹម ហ៊ុយ និងវ៉ាន់ ណាត

*

២) *ជនត្រូវចោទ ស្នើសុំការអនុញ្ញាតដើម្បីអាន__សេចក្តីប្រកាស__មួយ* ដែលបានរៀបចំតាក់តែងទុកជាមុន។ ភាគី ដែលត្រូវបានសហចៅក្រមស៊ើបអង្កេត ស្នើសុំឲ្យធ្វើចំណាប់អារម្មណ៍របស់ខ្លួន រួមមានមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណី បានស្នើថា ការអានសេចក្តីប្រកាសនេះ មិនត្រូវធ្វើទេ មុនពេលបញ្ចប់ការសំដែងឡើងវិញ។ សហព្រះរាជអាជ្ញាជំទាស់នឹងការអានសេចក្តីប្រកាស ដោយលើកហេតុផលថា ការធ្វើបែបនេះនឹងនាំឲ្យមានការឈឺចាប់ បន្ថែមទៅលើអ្វីដែលវាធ្ងន់ធ្ងរទៅហើយសំរាប់ជនរងគ្រោះ ហើយនឹងប៉ះពាល់ទៅដល់ដំណើរការនៃការប្រមូលភស្តុតាង។ ពួកគាត់យល់ថា យកល្អសេចក្តីប្រកាសនេះ គួរភ្ជាប់នឹងកំណត់ហេតុវិញ។ មេធាវីការពារក្តី គិតថា ជនត្រូវចោទមានទាំងសិទ្ធិបញ្ចេញមតិ និងសិទ្ធិនៅស្ងៀម និងថា ជនត្រូវចោទចង់និយាយនៅពេលចាប់ផ្តើមការសំដែងឡើងវិញ និងសុំអភ័យទោសស្របទៅតាមប្រពៃណីខ្មែរ ហើយការហាមឃាត់មិនឲ្យធ្វើបែបនេះ គឺជាការបំពានយ៉ាងធ្ងន់ធ្ងរទៅលើសិទ្ធិរបស់គាត់។ បន្ទាប់ពីបានពិភាក្សារួចមក សហចៅក្រមស៊ើបអង្កេតសំរេចថា ការអានសេចក្តីប្រកាសនឹងធ្វើនៅពេលបញ្ចប់ការសំដែងឡើងវិញ ប្រសិនបើពួកគាត់គិតថាជាការល្អ ហើយបើជនជាប់ចោទ នៅតែចង់អាននៅពេលនោះ។ ទោះបីជាយ៉ាងណាក៏ដោយ សេចក្តីប្រកាសនឹងត្រូវបានដាក់ចូលទៅក្នុងសំណុំរឿង។

៣) អ្នកចូលរួមទាំងអស់ ត្រូវបានអញ្ជើញឲ្យរៀបរាប់អំពីអ្វីដែលខ្លួនបានដឹង ទាក់ទិននឹងការ __ការមកដល់__ __ការចុះឈ្មោះ__ និង __ការថតរូបរបស់អ្នកទោស__។

៣.១ សាក្សី **សួស ធី** ពន្យល់ថាអ្នកទោសត្រូវបានគេដឹកយកមកតាមឡាន ដោយបិទមុខ ដៃជាប់ចំណង ហើយឈប់នៅខាងមុខទ្វារ [រូបថតល. ១៣]។ គឺកងរយដែលមាន **ប៉េង**, **ហ៊ុយ** និង **ស្រ៊ុ** ជាអ្នកទទួលបន្ទុកដឹកជញ្ជូន។

៣.២ សាក្សី **ហ៊ឹម ហ៊ុយ** ប្រកាសថាពេលខ្លះ អ្នកទោសត្រូវបានដឹកមកកាន់ ស២១ ពីតំបន់មួយចំនួនដោយអង្គភាពដែលបានចាប់ពួកគេ។ អ្នកទោសត្រូវបានគេដាក់ចុះនៅខាងក្រៅ។ ពេលខ្លះទៀត


Extraordinary Chambers in the Courts of Cambodia National Road 4 ,Chaom Chau , Dangkao Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax:023 218941
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Chaom CHau, Damgkao, Phnom Penh
Boite postale 71, Phnom Penh. Tel : Tel:+855(0)23 218914 Fax:023 218941

បុគ្គលិក ស២១ ចេញទៅយកអ្នកទោសដោយខ្លួនឯង។ ក្នុងករណីនេះ ឌុចប្រគល់ឈ្មោះឱ្យហ៊ី ហើយ ហ៊ី បញ្ជូនបន្តទៅឱ្យ ហ៊ីម ហ៊ុយ ដែលជាអ្នកចាប់ និងនាំមក។ ពេលខ្លះ អង្គភាពដើមបានចាប់រួច ហើយ ចំណែកឯបុគ្គលិក ស២១ គ្រាន់តែទៅនាំពួកគេមកទីនេះប៉ុណ្ណោះ។ **ហ៊ីម ហ៊ុយ** បញ្ជាក់ថា ម៉ម ណៃ និងប្រាក់ ខន មានភារកិច្ចផ្សេង និងមិនបានដឹងពីរឿងនេះទេ។ ហ៊ីម ហ៊ុយ ចង្អុលបង្ហាញថា ភារកិច្ចរបស់គាត់គឺយាមនៅ ស២១ ទទួល និងបញ្ជូនអ្នកទោសទៅឱ្យ សួស ធី។ សួស ធី កត់ឈ្មោះពួកគេ ហើយ ប៉េង នាំពួកគេទៅដាក់ក្នុងបន្ទប់ឃុំឃាំងនីមួយៗ។

៣.៣ សាក្សី **សួស ធី** បញ្ជាក់ថា បន្ទាប់ពីត្រូវបានដាក់ចុះពីឡាន អ្នកទោសដើររហូតដល់ច្រកចូល នៃអគារ E [រូបថតល.១៤ និងរូបថតល.១៥]។ បន្ទប់នេះ មិនមែនបិទជិតទេនិងមានតែកៅអីមួយមាន ភ្ជាក់ដៃសរសេរ ហើយមិនមានតុសរសេរទេ។ នៅទីនោះ គាត់រៀបចំបញ្ជីកត់ឈ្មោះ ដោយគាត់សួរ ឈ្មោះ ប្រវត្តិរូបសង្ខេប មុខរបរ អាសយដ្ឋានពួកគេ។ អ្នកទោសទាំងអស់បានគេវាស់កម្ពស់ទាំងអង្គុយ និង ឈរ ដោយប្រើឧបករណ៍ដែលបច្ចុប្បន្នកំពុងដាក់តាំងនៅជាន់ផ្ទាល់ដីនៃអគារ D នៃសារមន្ទីរ [រូបថតល.១៦, ល.១៧ និងល. ១៨]។ គេឱ្យអ្នកទោសនូវស្លាកលេខសំគាល់មួយ [រូបថតល.១៩]។ ពេលចុះបញ្ជីរួចហើយ សួស ធី បញ្ជូនពួកគេទៅឱ្យអ្នកថតរូបដែលនៅជាប់នោះ [រូបថតល.២០] ដែលនាសម័យនោះ បន្ទប់នោះតូចជាងនេះ ដោយសារមានជញ្ជាំងមួយដែលខណ្ឌវាជាពីរ។ ដូចដែល យើងអាចមើលឃើញការរៀបចំដាក់តាំងនៅជាន់ផ្ទាល់ដីនៃអគារ D រូបភាពខាងក្រោយរូបថត អាច ខុសៗគ្នា ពីព្រោះអាចពេលខ្លះរូបទាំងនេះ មិនបានថតនៅច្រកចូលទេ [រូបថតល.២១]។ គឺអ្នកថតរូប ជាអ្នកកំណត់លេខឱ្យពួកគេ [រូបថតល.២២]។ ជាទូទៅ គេប្តូរការដាក់លេខ រៀងរាល់ថ្ងៃ ប៉ុន្តែ ពេលខ្លះអ្នកថតរូបអាចរក្សាការដាក់លេខចំនួន បីថ្ងៃ។ រូបថតមិនត្រូវបានផ្តិតភ្លាមៗទេ ហើយទាល់តែ មួយ ឬពីរថ្ងៃក្រោយទើប សួស ធី មានរូបថតទាំងនោះ។ នៅពេលដែលការចុះឈ្មោះបានបញ្ចប់ មានអ្នកយាមផ្សេងទៀតមកនាំអ្នកទោសទៅក្នុងបន្ទប់ឃុំឃាំងរបស់ពួកគេ។ បន្ទាប់មកទៀត សួស ធី ចុះទៅពិនិត្យតាមអគារ C និង D (បន្ទប់ធំ និងតូច) ដើម្បីកត់លេខបន្ទប់របស់អ្នកទោស ហើយគាត់ បញ្ជូនលេខនេះទៅឱ្យអ្នកសួរចម្លើយ។



Extraordinary Chambers in the Courts of Cambodia National Road 4 ,Chaom Chau , Dangkao Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax:023 218941
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Chaom CHau, Damgkao, Phnom Penh
Boite postale 71, Phnom Penh. Tel : Tel:+855(0)23 218914 Fax:023 218941

៣.៤ ជនជាប់ចោទ អះអាងទទួលស្គាល់ការរៀបរាប់ទាំងនេះ ប៉ុន្តែបញ្ជាក់ថាគាត់ដាក់បញ្ហា តែម្យ៉ាងគត់គឺត្រូវមានរូបថត ៣ សន្លឹកសំរាប់អ្នកទោសម្នាក់ ដើម្បីបង្ការ និងដើម្បីស្វែងរកអ្នកទោសក្នុងករណីរត់គេច។ គាត់មិនបានដាក់បញ្ហាជាក់លាក់ផ្សេងទៀតទេ។

៣.៥ ដើមបណ្តឹងរដ្ឋប្បវេណី **ជុំ ម៉ី** ពន្យល់ថា នៅពេលគាត់មកដល់ គេនាំគាត់ទៅកន្លែងចុះឈ្មោះ។ គេបានដោះក្រមាបិទមុខចេញ មុននឹងសួរពីជីវប្រវត្តិរបស់គាត់។ គាត់មិនហ៊ានមើលមុខអ្នកដែលសួរគាត់ទេ ហើយមិនដឹងថាជា **សួស ធី** ឬមិនមែនទេ។ គាត់និយាយថា បន្ទាប់មកគេនាំគាត់ទៅថតរូបដែលនៅកន្លែងនោះគេឲ្យគាត់ដោះខោអាវ (នៅសល់តែខោទ្រនាប់) រួចហើយគេនាំគាត់ទៅបន្ទប់ឃុំឃាំងមួយ។

៣.៦ ដើមបណ្តឹងរដ្ឋប្បវេណី **ប៊ូ ម៉េង** បញ្ជាក់ថា ពេលមកដល់ បន្ទាប់ពីបានឆ្លងកាត់ខ្លោងទ្វារ គាត់និងប្រពន្ធ ត្រូវបានគេនាំទៅបន្ទប់ថតរូប។ គាត់បញ្ជាក់ថា តាំងតែពីពេលនោះមក គាត់មិនដែលបានជួបប្រពន្ធរបស់គាត់ទៀតទេ ហើយគាត់នៅសល់តែរូបថតប៉ុណ្ណោះ [រូបថតល.២៣]។ គាត់ពន្យល់ថាបន្ទាប់មកគេដាក់ខ្នោះគាត់ ហើយយកក្រណាត់ខ្មៅបិទមុខគាត់មុននឹងនាំគាត់ទៅអគារC។ គាត់បញ្ជាក់ថា គាត់ត្រូវបានគេធ្វើទារុណកម្មនៅខាងក្រៅ។ គាត់និយាយថា គាត់មិនត្រូវបានគេសួរពីប្រវត្តិរូបគាត់មុននឹងថតរូបទេ ដូច្នេះគាត់គិតថា ប្រហែលជាអង្គការស្គាល់ប្រវត្តិគាត់ពីមុន។ គាត់និយាយថាគាត់ភ័យខ្លាំងណាស់នាពេលនោះ ហើយគាត់មិនអាចចាំច្បាស់ទេ។

៣.៧ សាក្សី **ឆឹាន់ ឈរាត** ប្រកាសថា នៅពេលចុះពីឡាន គាត់ត្រូវបានគេដាក់ខ្នោះដែលធ្វើអំពីឈើ។ មុននឹងនាំទៅថតរូប គេបានសាកសួរគាត់ពីប្រវត្តិរូបរបស់គាត់។ អ្នកទោសជាប់ខ្នោះជាមួយគ្នានៅពេលថតរូប មានអ្នកទោសម្នាក់អង្គុយ ឯម្នាក់ទៀតឈរ ហើយគេផ្លាស់គ្នា។ នៅពេលថតចប់គេបិទមុខគាត់ ហើយនាំទៅជាន់ទីមួយនៃអគារ D (ជាន់ទី២ ខ្មែរ)។

*


Extraordinary Chambers in the Courts of Cambodia National Road 4 ,Chaom Chau , Dangkao Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax:023 218941
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Chaom CHau, Damgkao, Phnom Penh
Boite postale 71, Phnom Penh. Tel : Tel:+855(0)23 218914 Fax:023 218941

៤) អ្នកចូលរួមទាំងអស់ ត្រូវបានអញ្ជើញឱ្យកាន់ <u>**បន្ទប់ទី ២ នៃអគារ** E</u> (បន្ទប់ជាងគំនូរ) [រូបថតល.២៤]។

៤.១ សាក្សី **វ៉ាន់ ណាត** អះអាងទទួលស្គាល់ទីតាំងនៃបន្ទប់ដែលគាត់ធ្វើការ និងកន្លែងដែលជាងចម្លាក់ឈើស្ថិតនៅ។ គាត់អត្ថាធិប្បាយពីផ្ទាំងគំនូរមួយរបស់គាត់ គូរនៅឆ្នាំ ១៩៨៨ និងបានដាក់តាំងនៅទីនេះ ដែលបង្ហាញអំពីព្រឹត្តិការណ៍ ១៧ មេសា ១៩៧៥ នៅខេត្តបាត់ដំបង [រូបថត ល.២៥]។ គាត់បញ្ជាក់ថា គាត់មិនបានឃើញគេបោកក្មេងនឹងគល់ឈើដោយផ្ទាល់ភ្នែកទេ ប៉ុន្តែគាត់អះអាងថា អ្នកភ្នំសំពៅទាំងអស់ បានដឹងអំពីទង្វើបែបនេះ។

៤.២ ដើមបណ្តឹងរដ្ឋប្បវេណី **ប៊ូ ម៉េង** បញ្ជាក់អះអាង អំពីទីកន្លែងដែលជាងចម្លាក់ឈើ និងជាងគំនូរស្ថិតនៅ។ គាត់នៅចាំមុខរបស់ **ហ៊ឹម ហ៊ុយ** ដែលនៅថ្ងៃមួយ បានមើលគាត់តាមមាត់បង្អួច [រូបថត ល. ២៦]។

៤.៣ សាក្សី **ហ៊ឹម ហ៊ុយ** អះអាងទទួលស្គាល់ថាពិតជាមានរឿងដូច្នេះមែន ដោយនិយាយថា នៅពេលដែលគេបានសុំគាត់ឲ្យមកជួយ **ប៉េង** គាត់បានឆ្លៀតយកឱកាសនោះ ដើម្បីមើលជាងគំនូរតាមមាត់បង្អួច ។

៤.៤ **ជនត្រូវចោទ** អះអាងបញ្ជាក់អំពីភាពត្រឹមត្រូវនៃការពិពណ៌នារបស់ **ប៊ូ ម៉េង** និង **វ៉ាន់** ណាត។ គាត់ប្រកាសថា គឺពិតជាទីកន្លែងនេះហើយដែលគាត់មើលជាងគំនូរធ្វើការ។

៤.៥ ដើមបណ្តឹងរដ្ឋប្បវេណី **ប៊ូ ម៉េង** រៀបរាប់ពីហេតុការណ៍មួយដែលគាត់នៅចាំ៖ **ឌុច** អង្គុយនៅក្នុងបន្ទប់ជាងគំនូរ (មិនមែនបន្ទប់ជាងចម្លាក់ទេ)។ គាត់បានឲ្យបារីមួយកញ្ចប់ទៅ **ប៊ូ ម៉េង**។ បន្ទាប់មកទៀត ដោយគ្មានហេតុផលអ្វីទាំងអស់ គាត់បានឲ្យ **ប៊ូ ម៉េង** និង**អៀម ចាន់** វាយគ្នាទៅវិញទៅមកម្តងម្នាក់ដោយប្រើបំពង់ជ័រខ្មៅ។ **ប៊ូ ម៉េង** និង**អៀម ចាន់** ក៏ធ្វើតាមបញ្ជា ហើយ **ឌុច** អង្គុយមើល។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ។
Extraordinary Chambers in the Courts of Cambodia National Road 4 ,Chaom Chau , Dangkao Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax 023 218941
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Chaom CHau, Damgkao, Phnom Penh
Boite postale 71, Phnom Penh. Tel : Tel:+855(0)23 218914 Fax 023 218941

៤.៦ ជនត្រូវចោទ ទទួលស្គាល់ហេតុការណ៍នេះ ប៉ុន្តែមិនបានពន្យល់អំពីមូលហេតុអ្វីដែលខ្លួនធ្វើដូច្នេះទេ។

៤.៧ សាក្សី **វ៉ាន់ ណាត** រៀបរាប់អំពីសាច់រឿងនៃការធ្វើទារុណកម្ម ដែលគាត់បាបឃើញថា៖ ល្ងាចមួយ **ឌុច** នាំ "ជាងចម្លាក់ថ្មី" ម្នាក់ ដើម្បីមកធ្វើការសាកល្បង។ តាមការពិត ជនដែលនាំមកនេះជាជនជាតិវៀតណាម មិនចេះឆ្លាក់ទេ។ **ឌុច**សួរ គាត់ថាហេតុអ្វីបានជាគាត់ភរ ជនជាតិវៀតណាមនោះឆ្លើយថា គាត់អាចឆ្លាក់បានលុះត្រាតែបានជួបប្រពន្ធគាត់សិន។ ឌុចក៏ចាកចេញទៅវិញ បន្ទាប់មកអ្នកយាមម្នាក់ បាននាំជនជាតិវៀតណាមរូបនេះទៅធ្វើទារុណកម្មនៅក្នុងទីធ្លា។ តាមបង្អួចបន្ទប់របស់ជាងគំនូរ **វ៉ាន់ ណាត** អាចមើលឃើញគេវ៉ៃជនជាតិវៀតណាម រួចគេចងព្យួរជននោះនឹងតម្កក់នៃបង្គោលឡើងខ្សែព្លួរដែលស្ថិតនៅជ្រុងឈមគ្នារវាងអគារ A និងអគារ B [រូបថត ល.២៧] មុននឹងជ្រមុជទៅក្នុងពាងទឹក។ **វ៉ាន់ ណាត** និយាយថាគាត់មិនបានឃើញយូរទេ ដោយអ្នកយាមម្នាក់បានឃើញគាត់ ហើយក៏មកបិទបង្អួចទៅ។ គាត់បានបង្កើតសាច់រឿងនេះឡើងវិញ នៅក្នុងផ្ទាំងគំនូរមួយរបស់គាត់ [រូបថត ល.២៨] ។

*

**៥)** បន្ទាប់មក អ្នកចូលរួម ធ្វើដំណើរទៅកាន់អគារ A ដោយឆ្លងកាត់ជិតបង្គោលឡើងខ្សែព្លួរ និង**ផ្នូរខ្មោច** ដែលស្ថិតនៅចំពីមុខបង្គោលនោះ [រូបថត ល.២៩] ។ ទាក់ទិននឹងផ្នូរខ្មោចទាំងនេះ **ឌុច** ពន្យល់ថា នៅពេលជម្លៀសខ្លួនចេញពី ស ២១ មនុស្ស ៤ នាក់កំពុងត្រូវបានសួរចម្លើយ៖ គឺជាយុទ្ធជននៃអង្គភាព "យ ៨" ដែលបានបាញ់ស្មៀរបរទេស សម្លាប់ Malcom CALDWELL។ **ឌុច** *ប្រកាសថា បានបញ្ជូនបន្តបញ្ជារបស់* ***នួន ជា*** *ទៅអ្នកសួរចម្លើយឲ្យ "កំទេច" អ្នកទាំងបួននេះ។* បើតាម **ឌុច** សាកសពអ្នកទាំងនេះ ត្រូវបានទុកឲ្យស្ថិតនៅលើគ្រែ ដូចយើងបានឃើញក្នុងរូបថតខ្លះរបស់សារមន្ទីរ ហើយសាកសពទាំងនោះបានកប់នៅទីនេះជាមួយសាកសពផ្សេងទៀត។

៦) បន្ទាប់មក សាក្សី និងភាគីនានា អត្ថាធិប្បាយអំពីអ្វីដែលខ្លួនដឹង ទាក់ទិននឹង**អគារ A** ។

**៦.១** សាក្សី **វ៉ាន់ ណាត** ប្រកាសថា គាត់មិនដែលចូលក្នុងអគារ A នេះទេ។ ទិដ្ឋភាពរបស់អគារនេះមិនមានការផ្លាស់ទេ លើកលែងតែល្អសបន្ទាប់ណ្ណោះដែលនៅសម័យ ស ២១ គេដាក់បញ្ញើរ។

៦.២ សាក្សី **ហ៊ឹម ហ៊ុយ** បញ្ជាក់ថាពីដំបូងគេប្រើអគារនេះសំរាប់ឃុំឃាំង។ បន្ទាប់មកទៀត គាត់មិនបានដឹងថាគេប្រើសំរាប់សួរចម្លើយផងដែរទេ។

៦.៣ សាក្សី **សួស ធី** ពន្យល់ថា គាត់បានដឹងថា អគារ A គឺទុកសំរាប់ដាក់អ្នកទោសសំខាន់ ឬពិសេស (កម្មាភិបាលអ្នកដឹកនាំ)។

៦.៤ សាក្សី **គង់ ឆៃ** ពន្យល់ថា បន្ទាប់ពីគាត់ឈប់ទទួលបន្ទុកយាមនៅខាងក្រៅមក គាត់ត្រូវបានគេចាត់បញ្ជូនឲ្យទៅយាមនៅគុកពិសេស ដែលស្ថិតនៅពីក្រោយអគារ A។ គាត់និយាយថា គាត់បានឃើញ **ឌុច** មក និងសួរចម្លើយអ្នកទោសនៅគុកពិសេស។ អ្នកយាមនៅទីនេះមិនអាចចូលទៅគុកពិសេសទេ ប៉ុន្តែអ្នកយាមគុកពិសេសអាចចូលមកទីនេះបាន។ គាត់មកយាមនៅអគារនេះ ជិតពេលវៀតណាមចូលមកដល់។ គាត់ថាមិនស្គាល់ឈ្មោះអ្នកសួរចម្លើយទាំងអស់ទេ។ គាត់ពិពណ៌នាអំពីរបៀបនៃការធ្វើទារុណកម្ម (យកម្ជុលចាក់ក្រចកជើងអ្នកទោស, ជ្រមុជអ្នកទោសក្នុងទឹកកក) បន្ទាប់ពីការសួរចម្លើយ អ្នកទោសត្រូវបាន បញ្ជូនចេញ តែមិនដឹងទៅទីណាទេ។

៦.៥ សាក្សី **ម៉ម ណៃ** ប្រកាសថាគាត់មិនដឹងអ្វីទាំងអស់ពីអគារនេះ ព្រោះធម្មតា គាត់ធ្វើការនៅខាងក្រៅ។ តែគាត់ទទួលស្គាល់ថាធ្លាប់ចូលម្តងដើម្បីជួបអតីតសិស្សគាត់ឈ្មោះ **ផា ឡាំសៀង**។ ឌុច អះអាងថាពិតជាដូច្នេះមែន។

៦.៦ **ជនត្រូវចោទ** និយាយថាខ្លួនធ្លាប់មកអគារ A ពីរដង។ លើកទី១ មកជួប **វន វេត** ដែលត្រូវបានឃុំនៅជាន់ផ្ទាល់ដី (ជាន់ទី១ ខ្មែរ)៖ **វន វេត** ត្រូវបានចាប់ខ្លួននៅម៉ោង ១៨ ហើយព្រឹកឡើងម៉ោង ៧ ព្រឹក **ឌុច** បានទៅជួបគាត់ "ដើម្បីសុំអភ័យទោស និងសុំយោបល់គាត់ទាក់ទងនឹង **ប៉ុល ពត**"។ **ឌុច** បញ្ជាក់ថា **វន វេត** ត្រូវបានឃុំនៅជាន់ផ្ទាល់ដី (ជាន់ទី១ ខ្មែរ)។ លើកទី២ គឺនៅចុងឆ្នាំ១៩៧៨ គាត់ទៅជាមួយហ៊ី ដើម្បីជួប **ឡេង** បន្ទាប់ពីមានការចាប់ខ្លួន **ញឹ** នៅអង្គភាព ៧០៣ (ដើម្បីធានាគាត់ថាគាត់នឹងមិនត្រូវបានចាប់ខ្លួនទេ ទោះបីជា **ញឹ** ត្រូវបានចាប់ខ្លួនក៏ដោយ)។ **ឌុច** ប្រកាសថា គាត់មិនដឹងថាអតីតគ្រូរបស់គាត់ **កែ គឹមហួត** និងប្រពន្ធរបស់គាត់ ត្រូវបានឃុំនៅទីណាទេ។ តែគាត់បញ្ជាក់ថា ពួកគាត់ត្រូវបានសួរចម្លើយដោយ **ឌុយ** នៅខាងក្រោយអគារ A។



E.C.C.C * C.E.T.C * INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

៦.៧ ដើមបណ្ដឹងរដ្ឋប្បវេណី **ជុំ ម៉ី** អត្ថាធិប្បាយអំពីស្ថានភាពនៃការធ្វើទារុណកម្មដែលគាត់បានទទួលនៅក្នុងអគារនេះ។ ខណៈពេលដែលគាត់កំពុងជាប់ឃុំនៅក្នុងគុកតូចធ្វើអំពីឥដ្ឋ ស្ថិតនៅក្នុងអគារ C (យោងទៅកថាខណ្ឌ ៩.២ ខាងក្រោម) គាត់ត្រូវបានគេនាំខ្លួនមកកាន់បន្ទប់ទី ៤ ជាន់លើបង្អស់នៃអគារ A អស់រយៈពេល ១២ថ្ងៃ ១២យប់។ គាត់មកដល់ដោយបិទមុខ និងជាប់ខ្នោះ ដោយស្លៀកតែខោខ្លី។ គេបានដាក់ឱ្យគាត់អង្គុយផ្ទាល់ឥដ្ឋការ៉ូ បន្ទាប់មកគេដោះខ្នោះ និងដកក្រណាត់រុំមុខចេញ។ គាត់បានឃើញឈាមស្រស់គ្រប់កន្លែង។ នៅខាងស្ដាំដៃគាត់ គាត់ឃើញមានតុតូចមួយ មានម៉ាស៊ីនអង្គុលីលេខ មានរំពាត់ និងខ្សែភ្លើងជាច្រើន។ នៅសម័យនោះ មិនមានគ្រែទេ [រូបថត ល.៣០] ។ អ្នកសួរចម្លើយ បានសួរគាត់ថាតើគាត់ជាភ្នាក់ងារ CIA ឬ KGB។ ពេលគាត់ឆ្លើយថាគាត់មិនដឹងថា *CIA ឬ KGB ជាអ្វីទេ អ្នកសួរចម្លើយ បានកញ្ឆក់យករំពាត់ ហើយវាយគាត់*។ ដោយសារគាត់បានលើកដៃរងកុំឱ្យគេវាយ ធ្វើឱ្យកូនដៃមួយរបស់គាត់បាក់រហូតដល់បច្ចុប្បន្ន។ បន្ទាប់មក អ្នកសួរបានចាប់ផ្ដើមដកក្រចកជើងរបស់គាត់ និងបានយកខ្សែភ្លើងមកចាប់នឹងត្រចៀករបស់គាត់ ហើយឆក់គាត់ ២ ដងបណ្ដាលឱ្យគាត់សន្លប់បាត់ស្មារតី។ ជុំ ម៉ី ពន្យល់ថានៅពេលដែលគាត់មិនអាចទ្រាំទ្រនឹងទារុណកម្ម និងការឆក់ខ្សែភ្លើងទៀតបានគាត់ក៏ចាប់ផ្ដើមកុហក ហើយឆ្លើយដាក់បុគ្គលផ្សេងទៀត។ ជុំ ម៉ី អះអាងថា **សេង, ទិត** និងហ៊ី បានធ្វើទារុណកម្មគាត់។ គាត់មិនដឹងថាតើបន្ទប់នេះប្រើសំរាប់សួរចម្លើយ ឬក៏សំរាប់ឃុំឃាំង ផងដែរទេ។ គាត់បញ្ជាក់ថាគាត់មិនបានដឹងពីអ្វីដែលកើតមាន នៅជាន់ខាងក្រោមទេ ប៉ុន្តែថានៅកន្លែងដែលគេធ្វើទារុណកម្មគាត់ អ្នកទោសទាំងអស់សុទ្ធតែជាប់ខ្នោះព្រមទាំងមានជើងជាប់ច្រវាក់។

៦.៨ ***ឌុច*** គូសបញ្ជាក់ថា ការរៀបរាប់របស់ ជុំ ម៉ី មិនមានលក្ខណៈហួសហេតុពន្លើសទេ ហើយសុំទោសចំពោះ ជុំ ម៉ី។ ឌុច បន្ថែមថា ការសួរចំលើយ ជុំ ម៉ី ធ្វើនៅក្នុងអគារនេះ ដែលតាមធម្មតាទុកសំរាប់សួរអ្នកទោសសំខាន់ ឬជនបរទេស ប្រហែលជាមកពីមានកំហុសឆ្គង ឬ ការភាន់ច្រឡំដែលកើតមាននៅពេលគាត់មកដល់។

៧. ការសំដែងឡើងវិញ បានផ្អាកនៅវេលាម៉ោង ១១ និង៥០ នាទី ហើយចាប់ផ្ដើមសារជាថ្មីនៅវេលាម៉ោង ១៣ និង២០ នាទី

*

៨. អ្នកចូលរួមធ្វើដំណើរទៅកាន់ ជាន់ផ្ទាល់ដី នៃ អគារ D ដែលនៅទីនោះ មានការដាក់តាំងនូវឧបករណ៍ និងរូបថតជាច្រើន។

៨.១ ដោយបង្ហាញរូបថតក្រុមកម្មាភិបាលខ្មែរក្រហម [រូបថត ល. ៣១ និង៣១ ស្ទួន] ៖ **ជនត្រូវចោទ** ពន្យល់ថា រូបថតនេះ ត្រូវបានគេថតនៅ ខែមិថុនា ឆ្នាំ១៩៧៦ នៅក្បែរផ្ទះរបស់គាត់ (ជាផ្ទះលេខ៤ ដែលមាននៅលើប្លង់ដែលខ្លួនបានប្រគល់ជូនកាលពីសួរចម្លើយកន្លងមក)។ **ឌុច**នៅចាំបានរូប **ម៉ម ណៃ** និងប្រពន្ធ ព្រមទាំងកូនស្រី (**ម៉ម ណៃ** ក៏យល់ស្របដែរ)។ នៅលើរូបថត **ឌុច** ក៏បានចង្អុលបង្ហាញផងដែរនូវរូបខ្លួនឯង និងប្រពន្ធ, រូប **យូ ប៉េងគ្រី** ហៅម៉ុន និងប្រពន្ធ, រូប **ម៉ា ម៉េងឃាង** និងប្រពន្ធ។ **ឌុច** ពន្យល់ថា មានការជួបជុំគ្រួសារកម្មាភិបាលដែលបានរៀបការហើយចំនួនបីដងក្នុងមួយខែ ក្នុងរវាងដប់ថ្ងៃម្តង ហើយថាមិនមានរូប **ហ៊ី**, **ប៉ុន** និង**ហ៊ុយ** នៅក្នុងរូបថតនេះទេ ដោយសារពួកគេមិនទាន់រៀបការនៅឡើយទេ។ ចំណែក **ណាត** វិញបានចាកចេញបាត់ទៅហើយ។

ដោយបង្ហាញរូបថតបុរសម្នាក់អង្គុយមានជើងជាប់ខ្នោះ៖ ជនត្រូវចោទ ពន្យល់ថាគឺជារូប **កុយ ធួន** ដែលត្រូវបានឃុំឃាំងនៅក្នុងគុកពិសេស [រូបថត ល.៣២] ។ រូបនេះ ត្រូវបានថតនៅពេលដែល **ឌុច** ទៅសួរចម្លើយ **កុយ ធួន**។ **ជនត្រូវចោទ** រៀបរាប់សារជាថ្មីថា ក្រោយពីបានកាច់បិចបាក់អស់បីរួចមក **កុយ ធួន** ចាប់ផ្តើមសរសេរ។

**ឌុច** ក៏ចង្អុលបង្ហាញរូប **ឃឹម វ៉ាត** ហៅ **ហ៊ី** ដែលមាននៅក្នុងរូបថតមួយសន្លឹកផងដែរ [រូបថត ល.៣៣] ។

នៅពេលសួរអំពីរូបថតបុរសម្នាក់ដេកស្តូកស្តឹងនៅនឹងដី លើផ្លូវដើរ ក្បែរពាងទឹកមួយ [រូបថត ល.៣៤]៖ **ឌុច** ប្រកាសថា គាត់មិនដឹងរឿងអ្វីទាល់តែសោះអំពីរូបថតនោះ។ **សួស ធី** ផ្តល់គំនិតថា នេះប្រហែលជារូបថតអ្នកជំងឺម្នាក់ដែលស្លាប់នៅក្នុងបន្ទប់ឃុំឃាំង។ បើយោងតាម **សួស ធី** រូបថតបែបនេះត្រូវបានធ្វើឡើងសំរាប់ទុកជាភស្តុតាង នៅពេលមានការសួរពីករណីបាត់អ្នកទោស។

**៨.២ ជុំ ម៉ី** បង្ហាញរូបថតមួយ ដោយបញ្ជាក់ថា រូបនេះត្រូវបានថតដោយជនជាតិអាឡឺម៉ង់ នៅឆ្នាំ១៩៨១ នៅពីមុខអគារ C នាឆ្នាំ១៩៨១ [រូបថត ល.៣៥]។ គាត់ចង្អុលប្រាប់រូបថត **វ៉ាន់ ណាត**, **ប៊ូ ម៉េង**, **ជុំ ម៉ី** និងតា **គង់** និងខ្លួនគាត់ ហើយពន្យល់ថាអ្នកថតរូបជនជាតិអាឡឺម៉ង់ បានមកកាន់



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ។
Extraordinary Chambers in the Courts of Cambodia National Road 4 ,Chaom Chau , Dangkao Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax 023 218941
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Chaom CHau, Damgkao, Phnom Penh
Boite postale 71, Phnom Penh. Tel : Tel:+855(0)23 218914 Fax:023 218941

ទីនេះជាលើកទីមួយ ដើម្បីប្រមូលយករូបថតទៅ "បង្ហាញដល់អង្គការសហប្រជាជាតិ"។ ដោយសារអង្គការនេះមិនជឿ អ្នកថតរូបនេះក៏វិលត្រលប់មកម្តងទៀត ដើម្បីមកថតរូបសាជាថ្មីវិញ។ ដូច្នេះ រូបនេះត្រូវបានថតនាឱកាសនោះហើយ។

៨.៣ នៅក្នុងបន្ទប់ទី ២ នៃជាន់ផ្ទាល់ដីនៃអគារ D សាក្សី **វ៉ាន់ ណាត** អត្ថាធិប្បាយពីផ្ទាំងគំនូររបស់គាត់មួយចំនួន។ ទាក់ទិននឹងផ្ទាំងគំនូរ ដែលបង្ហាញពីក្មេងម្នាក់ត្រូវបានទាញកន្ត្រាក់ចេញពីដៃម្តាយ [រូបថត ល.៣៦] គាត់បញ្ជាក់ថា គាត់មិនបានឃើញទិដ្ឋភាពទាំងនេះដោយផ្ទាល់ភ្នែករបស់គាត់ទេ។ គាត់គ្រាន់តែបានលឺសម្លេងស្រែករបស់កុមារ និងស្ត្រី។ ឆ្លងចេញពីសម្រែកទាំងនេះហើយ ទើបគាត់ធ្វើការស្រមើស្រមៃ និងគូររូបនេះចេញមក។ គាត់ពន្យល់ទៀតថា គាត់បានឃើញ **ហ៊ឹម ហ៊ុយ** និងមនុស្សបីនាក់ទៀត ឡើងទៅកាន់បន្ទប់មួយនៅជាន់ខាងលើ រួចចុះមកវិញជាមួយកូនក្មេង។

៨.៤ សាក្សី **ហ៊ឹម ហ៊ុយ** និយាយថាគឺ **ប៉េង** និងស្រ៊ី ទេជាអ្នកទទួលខុសត្រូវខាងកុមារ ចំណែកគាត់មិនដែលធ្វើការងារបែបនេះទេ។ គាត់មិនដែលបានចូលទៅក្នុងបន្ទប់សួរចម្លើយកុមារ និងស្ត្រីម្តងណាឡើយ។ **វ៉ាន់** ណាត អះអាងថា គាត់ប្រាកដច្បាស់ក្នុងចិត្តណាស់ថា **ហ៊ឹម ហ៊ុយ** ព្រមទាំងមនុស្សពីរ បីនាក់ផ្សេងទៀត បានឡើង រួចចុះមកវិញជាមួយកូនក្មេង។

៨.៥ ទាក់ទិននឹងផ្ទាំងគំនូរ ដែលបង្ហាញពីអ្នកទោសម្នាក់ត្រូវបានគេសែងព្យួរដៃ និងជើង [រូបថត ល.៣៧] **វ៉ាន់ ណាត** ប្រាប់ថាគាត់បានឃើញទិដ្ឋភាពនេះដោយផ្ទាល់ភ្នែកគាត់ ៖ គឺជាអ្នកទោសដែលដើរលែងរួច។

៨.៦ បន្ទាប់មកសាក្សី **វ៉ាន់ ណាត** ពន្យល់ថា គាត់គូរផ្ទាំងគំនូរដែលបង្ហាញពីអ្នកទោសត្រូវវាយដោយរំពាត់ខ្សែតី [រូបថត ល.៣៨] នេះឡើង តាមសំណើរបស់ **ប៊ូ ម៉េង** ដែលជាអ្នកពិពណ៌នាទិដ្ឋភាពនេះប្រាប់គាត់។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ។
Extraordinary Chambers in the Courts of Cambodia National Road 4 ,Chaom Chau , Dangkao Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax:023 218941
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Chaom CHau, Damgkao, Phnom Penh
Boite postale 71, Phnom Penh. Tel : Tel:+855(0)23 218914 Fax:023 218941

E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

៨.៧ ដើមបណ្តឹងរដ្ឋប្បវេណី **ម៉ឺ ម៉េង** អះអាងថាពិតជាដូច្នេះមែន។ គាត់ពន្យល់អំពីរបៀបដែលគាត់ត្រូវបានគេធ្វើទារុណកម្ម៖ គាត់ត្រូវបានគេបញ្ជាឲ្យគាត់ដេកសណ្តូកជើង។ គាត់អះអាងថាគឺ **ហ៊ឹម ហ៊ុយ, ប៉េង, ទិត, ម៉ម ណៃ** និង **ហួរ** បានវាយគាត់នឹងរំពាត់ឫស្សី និងរំពាត់ផ្តៅ។ គាត់រៀបរាប់ថា គេបានបង្ហាញគាត់នូវរំពាត់មួយបាច់ ហើយបញ្ជាឲ្យគាត់ជ្រើសរើសរំពាត់ណាមួយសម្រាប់ឲ្យពួកគេយកទៅវាយគាត់។ គាត់ពន្យល់ថា ពួកគេបានវាយខ្នងគាត់ ហើយគាត់បានងាកខ្លួនចេញដើម្បីគេចពីរំពាត់ ហើយត្រូវរងរបួសនៅកន្លែងផ្សេងវិញ។ គាត់បង្ហាញស្នាមដំបៅចាស់នៅលើខ្នងរបស់គាត់។ គាត់បញ្ជាក់ថា ពួកវាខ្លះនិយាយថា៖ *«កុំធ្វើទារុណកម្មវាដល់ស្លាប់ឲ្យសោះ។ យើងត្រូវការវាទុកគូររូបប៉ុល ពត»*។

៨.៨ សាក្សី **ម៉ម ណៃ** ប្រកាសថា គាត់ចាំមិនបានទេថាតើគាត់បានចូលរួមសួរចម្លើយអ្នកទោសជាមួយ **ប៉េង, ទិត** ឬក៏ **ហួរ** ទេ។ ភារកិច្ចរបស់គាត់ គឺសួរចម្លើយតែអ្នកទោសជនជាតិវៀតណាមប៉ុណ្ណោះ។

៨.៩ សាក្សី **ហ៊ឹម ហ៊ុយ** ទទួលស្គាល់ថាគាត់បានចូលរួមក្នុងការសួរចម្លើយ និងធ្វើទារុណកម្ម។ គាត់បញ្ជាក់ថែមទៀតថា តាមធម្មតា គាត់មិនត្រូវចូលរួមសួរចម្លើយទេ គឺគ្រាន់តែយាមទ្វារនៅបរិវេណខាងក្រៅប៉ុណ្ណោះ។ គាត់និយាយថា គាត់ "បានភ្លេចរឿងនេះអស់ទៅហើយ តែគាត់នៅតែទទួលស្គាល់ដដែល"។

៨.១០ ទាក់ទិននឹងផ្ទាំងគំនូរដែលបង្ហាញពីអ្នកទោសដេកតម្រៀបជាជួរ [រូបថត ល.៣៩] **វ៉ាន់ ណាត** ពន្យល់ថា គាត់ត្រូវបានគេឃុំនៅជាន់លើនៃអគារក្នុងបន្ទប់មួយដែលមានសភាពបែបនេះ (យោងទៅកឋាខណ្ឌ ៩.១ ខាងក្រោម)។ សាក្សី **ប្រាក់ ខន** និង **គង់ ផៃ** ទទួលស្គាល់ថាពិតជាមានបន្ទប់របៀបនេះប្រាកដមែន។ **សួស ធី** ពន្យល់ថា មានបន្ទប់ប្រភេទនេះជាច្រើន។ **ម៉ម ណៃ** ប្រកាសថា គាត់មិនដែលបានចូលក្នុងបន្ទប់បែបនេះទេ។

៨.១១ ទាក់ទិននឹងផ្ទាំងគំនូរដែលបង្ហាញពីមនុស្សដែលត្រូវគេបិទមុខ [រូបថត ល.៤០] **វ៉ាន់ ណាត** ពន្យល់ថា ផ្ទាំងគំនូរនេះឆ្លុះបញ្ចាំងពីការសម្លាប់មនុស្សមួយនៅជើងឯក។ គាត់បញ្ជាក់ថា គាត់មិនដែល



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ។
Extraordinary Chambers in the Courts of Cambodia National Road 4 ,Chaom Chau , Dangkao Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax:023 218941
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Chaom CHau, Damgkao, Phnom Penh
Boite postale 71, Phnom Penh. Tel : Tel:+855(0)23 218914 Fax:023 218941

ជួបប្រទះដោយផ្ទាល់ភ្នែកនូវទិដ្ឋភាពបែបនេះទេ តែគាត់បានគូរផ្ទាំងគំនូរនេះឡើងដោយផ្អែកលើឯកសារ និងដំណើរទស្សនកិច្ចរបស់គាត់នៅជើងឯក នាឆ្នាំ១៩៧៩។

៨.១២ នៅក្នុងបន្ទប់ទីបី ជាន់ផ្ទាល់ដីនៃអគារ D ឧបករណ៍ធ្វើទារុណកម្មផ្សេងៗ ត្រូវបានដាក់តាំង [រូបថត ល.៤១]។ **ជនត្រូវចោទ** ពន្យល់ថា ការជ្រើសរើសឧបករណ៍សំរាប់ធ្វើទារុណកម្ម គឺអាស្រ័យលើអ្នកសួរចម្លើយ។ សាក្សី **ប្រាក់ ខន** ទទួលស្គាល់ថា ពិតជាឧបករណ៍ទារុណកម្ម ដែលបានប្រើប្រាស់នៅមន្ទីរ ស.២១ មែន ដោយបញ្ជាក់ថា ខ្លួនគាត់ផ្ទាល់មិនដែលបានប្រើឧបករណ៍ទាំងអស់នេះទេ។ គាត់បញ្ជាក់ថា *"កាំបិត និងពូថៅ ត្រូវបានប្រើសំដៅបំភ័យអ្នកទោសតែប៉ុណ្ណោះ។ គេអាចធ្វើទារុណកម្មតិចតួច តែមិនត្រូវធ្វើអោយមានការប៉ះពាល់ធ្ងន់ធ្ងរទេ។ បើសិនជាអ្នកណាធ្វើឱ្យគេស្លាប់ គឺអ្នកនោះជាអ្នកទទួលខុសត្រូវ។ ទាក់ទិននឹងឧបករណ៍សម្លាប់មនុស្ស ខ្ញុំមិនបានដឹងទេ ព្រោះខ្ញុំគ្រាន់តែជាអ្នកសួរចម្លើយប៉ុណ្ណោះ"*។ សាក្សី **ម៉ម ណៃ** ប្រកាសថា គាត់ធ្លាប់ប្រើតែរំពាត់ និងខ្សែភ្លើងតែប៉ុណ្ណោះ។

៨.១៣ សាក្សី **ហ៊ឹម ហ៊ុយ** ពន្យល់ថា ដើម្បីសម្លាប់មនុស្ស គេវាយកញ្ចឹងកអ្នកទោសនឹងដំបងដែក។ បន្ទាប់ពីវាយរួចហើយ គេអារកអ្នកទោសនឹងផាងត្នោត។ គេប្រើប៉ែលដើម្បីជីករណ្ដៅកប់អ្នកទោស។ គេប្រើចបត្រសេះ សំរាប់ដីដែលរឹង។

៨.១៤ នៅចំពោះមុខអាងត្រាំទឹក [រូបថត ល.៤២] សាក្សី **ម៉ម ណៃ** សាក្សី **ប្រាក់ ខន** និង សាក្សី **សួស ធី** ប្រកាសថា ពួកគេមិនដឹងថាមានអាងត្រាំទឹកនេះទេ។ ផ្ទុយទៅវិញ សាក្សី **ឡេង ឆៃ** ពន្យល់ថា គាត់បានឃើញអាងត្រាំទឹកបែបនេះនៅខាងក្រៅបរិវេណគុក គឺនៅក្នុងគុកពិសេស។ គាត់បន្ថែមថា ធុងឈើដែលដាក់តាំងនៅជិតអាងត្រាំទឹក ត្រូវបានបំពេញដោយទឹកកកត្រជាក់។ **ជនត្រូវចោទ** អះអាងថា គាត់មិនធ្លាប់បានឃើញឧបករណ៍ប្រភេទនេះទេ នៅពេលដែលគាត់ចូលទៅក្នុងផ្ទះដែលជាទីកន្លែងសួរចម្លើយរបស់កងកម្លាំងពិសេស។ គាត់បន្ថែមថា គាត់មិនដែលបញ្ជាឲ្យគេប្រើអាងត្រាំទឹកនេះទេ ហើយក៏មិនដែលទទួលបានព័ត៌មានអំពីការប្រើប្រាស់អាងនេះនៅក្នុងរបាយការណ៍ដែរ។ នៅចំពោះមុខផ្ទាំងគំនូររូបអាងងូតទឹក [រូបថត ល.៤៣] សាក្សី **ម៉ាន់ ណារាត** ពន្យល់ថា អ្នកបកប្រែជនជាតិវៀតណាមម្នាក់ដែលបានស្លាប់ទៅហើយ បាននិយាយអះអាងប្រាប់គាត់ថា រូបគេបានទទួលរង



Extraordinary Chambers in the Courts of Cambodia National Road 4 ,Chaom Chau , Dangkao Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax:023 218941
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Chaom CHau, Damgkao, Phnom Penh
Boite postale 71, Phnom Penh. Tel : Tel:+855(0)23 218914 Fax:023 218941

ទារុណកម្មនៅក្នុងអាងត្រាំទឹកនេះ។ គាត់បានគូររូបបង្ហាញពីអាងងូតទឹកនេះ ដោយផ្អែកលើព័ត៌មានដែលគាត់ទទួលបានពីបុរសនោះ ប៉ុន្តែខ្លួនគាត់មិនដែលបានឃើញគេប្រើឧបករណ៍ប្រភេទនេះទេ។

៨.១៥ នៅចំពោះមុខផ្ទាំងគំនូរដកក្រចកអ្នកទោស [រូបថត ល.៤៤] សាក្សី **វ៉ាន់ ណាត** គូសបញ្ជាក់ថា គាត់បានគូរផ្ទាំងគំនូរនេះដោយផ្អែកលើដំណើររនិទានរបស់អ្នកទោសម្នាក់ឈ្មោះ **អ៊ឹង** ពេជ្រ ជាជាងម៉ាស៊ីន ដែលបានប្រាប់គាត់ថា ខ្លួនទទួលរងទារុណកម្មបែបនេះ ហើយគេបានចាក់អាល់កុលពីលើថែមទៀត។

*

៩. បន្ទាប់មកទៀត ជនរងគ្រោះ ត្រូវបានអញ្ជើញឱ្យបញ្ជាក់អំពីស្ថានភាពនៃការឃុំខ្លួនរបស់ពួកគេ និងឱ្យកំណត់ពីទីតាំងនៃបន្ទប់ដែលពួកគេជាប់ឃុំ។

៩. ១ នៅក្នុងបន្ទប់ទីបួន ជាន់ផ្ទាល់ដីនៃអគារ D សាក្សី **វ៉ាន់ ណាត** ចង្អុលបង្ហាញថា គាត់ត្រូវបានគេឃុំនៅក្នុងបន្ទប់ដែលមានស្លាកសរសេរថា «ផ្ទះលេខ៤»។ គាត់ពន្យល់ថា នៅសម័យនោះ អ្នកទោសត្រូវបានគេដាក់ខ្នោះតជាប់គ្នាជាជួរៗនៅសងខាងខ្សែខ្នោះទីមួយ ចំណែកឯខ្សែខ្នោះទីពីរមានអ្នកទោសតែមួយជួរទេ ដូចដែលមាន បង្ហាញក្នុងផ្ទាំងគំនូរស្រាប់ [រូបថត ល.៣៩]។ មានកេះមួយសំរាប់ដាក់លាមកនៅក្បែរទ្វារ។ ចំនួនអ្នកទោសប្រែប្រួលទៅតាមថ្ងៃ ពី៤០ ទៅ ៦០នាក់។ **វ៉ាន់** ណាត ពន្យល់ថា គាត់បានស្ថិតនៅក្នុងបន្ទប់នេះរយៈពេលមួយខែ។ គាត់បញ្ជាក់ទៀតថា អ្នកយាមធ្វើការផ្លាស់ប្តូរវេនគ្នាជារៀងរាល់ថ្ងៃ។ ក្រោយមក **ឌុច** បានបញ្ជាឱ្យគាត់ទៅធ្វើការ។ គាត់ធ្វើការពេលថ្ងៃនៅក្នុងបន្ទប់ជាងគំនូរ និងជាងចម្លាក់ (ជាន់ផ្ទាល់ដីនៃអគារ E)។ ពេលល្ងាច គាត់ដេកនៅលើកន្ទេលក្នុងបន្ទប់តូចនៅជាន់ទី១ (ជាន់ទី២ ខ្មែរ) នៃអគារ C ដោយមិនមានជាប់ខ្នោះទេ។

៩. ២ ដើមបណ្តឹងរដ្ឋប្បវេណី **ជុំ ម៉ី** រៀបរាប់ថា បន្ទាប់ពីគេបានចុះបញ្ជី និងថតរូបគាត់ហើយនៅប្រហែលជាម៉ោង ១១ ព្រឹក គេបាននាំគាត់មកក្នុងបន្ទប់ឃុំឃាំងតូចមួយធ្វើអំពីឥដ្ឋនៅជាន់ផ្ទាល់ដីនៃអគារ D [រូបថត ល.៤៥] ដែលនៅទីនោះ គាត់ត្រូវបានគេឃុំអស់រយៈពេល ១២ ថ្ងៃ និង ១២ យប់។ គាត់រៀបរាប់ថា គាត់ត្រូវបានគេឱ្យអង្គុយចុះ ជើងរបស់គាត់ត្រូវបានដាក់ខ្នោះ

បន្ទាប់មកគេបានស្រាយក្រមារុំមុខ និងដោះខ្នោះដៃគាត់ចេញ [រូបថត ល.៤៦]។ គាត់ពន្យល់ថា នៅពេលដែលគេដាក់ខ្នោះគាត់ហើយ គាត់មិនអាចងើបឈរបានទេ។ ពេលបន្ទោរបង់ គាត់ត្រូវបន្ទោរបង់ដាក់កេះ។ នៅពេលយប់ គាត់អាចសុំអ្នកយាម ដើម្បីប្រែខ្លួនបាន។ ប្រសិនបើគេប្រែខ្លួនដោយធ្វើឱ្យមានសម្លេង និងដោយមិនបានសុំអ្នកយាមជាមុន គេនឹងត្រូវគេវាយ ២០០ រំពាត់។ គាត់ មិនមានសម្លៀកបំពាក់ទេ គឺមានតែខោខ្លីមួយ ហើយគាត់ដេកផ្ទាល់នឹងដីតែម្តង។ គាត់ទទួលបានតែបបររាវពីរវែកប៉ុណ្ណោះសំរាប់របបអាហាររបស់គាត់ ហើយគាត់ស្គមខ្លាំងណាស់ និងត្រូវបានមូសខាំយ៉ាងច្រើន ធ្វើឱ្យគាត់ពិបាកទ្រាំណាស់។ គាត់គូសបញ្ជាក់ទៀតថា ពួកអ្នកយាមជះទឹកដាក់អ្នកទោសនៅក្នុងបន្ទប់ឃុំឃាំងនីមួយៗដើម្បីឱ្យពួកគេលុបលាងខ្លួន។ នៅពេលនោះ គាត់ត្រូវបានគេធ្វើទារុណកម្ម និងសួរចម្លើយនៅក្នុងបន្ទប់ទី ៤ ជាន់លើបង្អស់នៃអគារ A (សូមអានកថាខណ្ឌ ៦.៧ ខាងលើ)៖ គាត់ត្រូវបានគេយកមកដាក់ក្នុងបន្ទប់ឃុំឃាំងធ្វើពីឥដ្ឋនេះវិញ នៅពេលគេសួរចម្លើយគាត់ចប់។ គាត់អះអាងបន្ថែមថា បន្ទប់នេះគឺនៅដដែល មិនការប្រែប្រួលអ្វី (លើកលែងតែចម្រឹងដែកប៉ុណ្ណោះដែលគេដាក់បន្ថែម)។ បន្ទាប់ពីការធ្វើទារុណកម្មរួច ដោយគាត់បានសារភាពអស់ហើយ គេបានបញ្ជូនគាត់ទៅក្នុងបន្ទប់ធំមួយនៅជាន់លើបង្អស់នៃអគារដដែល ដែលនៅទីនោះគេបានដាក់ខ្នោះអ្នកទោសតៗគ្នា។ គាត់បាននៅទីនោះរហូតដល់ថ្ងៃរំដោះ។ គាត់ត្រូវបានគេឃុំ ដោយគេដាក់ជើងគាត់ជាប់នឹងរនុកដែក និងនៅពេលព្រឹកមុនគាត់ចេញទៅរោងជាងជួសជុលម៉ាស៊ីនដេរ គេដោះវាចេញ។ គាត់បញ្ជាក់ថា នៅពេលនោះ គាត់មិនបានស្គាល់ **ប៊ូ ម៉េង** ទេ។

**៩.៣** ដើមបណ្តឹងរដ្ឋប្បវេណី **ជុំ ម៉េង** ពន្យល់ថា បន្ទាប់ពីចុះឈ្មោះហើយ គេបាននាំគាត់មកបន្ទប់ទី១ ខាងស្តាំ នៅជាន់លើបង្អស់នៃអគារ C [រូបថត ល.៤៧]។ នៅត្រង់លេខ ១៣ គាត់ត្រូវបានគេដាក់ខ្នោះដែលតំរៀបគ្នាជាជួរ [រូបថត ល.៤៨]។ នៅពេលដែលគាត់ងាកទៅក្រោយទៅ គាត់បានឃើញពួកអ្នកយាមបានឡើងជាន់លើទ្រូងរបស់ជនបរទេសម្នាក់ (អាចជាជនជាតិ បារាំង អាមេរិកាំង ឬអូស្ត្រាលី) ធ្វើឱ្យមានឈាមចេញពីមាត់ ហើយជនបរទេសនោះក៏ស្លាប់ បន្ទាប់មកគេក៏បានយកសាកសពជនបរទេសនោះទៅកប់។ បើតាមការស្មានរបស់ **ប៊ូ ម៉េង** ប្រហែលជាមានអ្នកទោសពី ៣០ ទៅ ៤០ នាក់។ **ប៊ូ ម៉េង** បញ្ជាក់អះអាងថា អ្នកទោសមានកេះមួយសំរាប់ដាក់លាមក និងប៊ីដុងទឹកមួយសម្រាប់ដាក់ទឹកនោម [រូបថត ល.៤៩], ពួកគេដេករាបផ្ទាល់ដីដោយមានតែខោខ្លីមួយប៉ុណ្ណោះ

ជាសម្លៀកបំពាក់ ហើយពួកគេទទួលបានតែបបរាវមួយវែកម្នាក់ៗ និងថា ដើម្បីលុបលាងខ្លួន អ្នកយាមយកទឹកមកជះលើអ្នកទោសម្នាក់ៗ ហើយទឹកហូរតាមប្រហោងមួយ [រូបថត ល.៤៧]។ ប៊ូ ម៉េង គូសបញ្ជាក់ថា គាត់នៅក្នុងសភាពបែបនោះមួយថ្ងៃរាល់ល្ងាច អស់រយៈពេលប្រហែលជាប្រាំមួយខែ រហូតដល់ថ្ងៃមួយ មានអ្នកយាមម្នាក់មក ហើយបានសួរថា មាននរណាម្នាក់ចេះគូររូបទេ។ គឺចាប់ពីពេលនោះហើយដែលគាត់បានធ្វើការ និងដេកនៅក្នុងបន្ទប់ជាងគំនូរ។

៩.៤ សាក្សី **ម៉ាន់ ឈាន** បញ្ជាក់ថា គាត់មកដល់ក្នុងបន្ទប់នេះនៅថ្ងៃទី ៥ ខែកុម្ភៈ ឆ្នាំ ១៩៧៨ ហើយគាត់នៅទីនោះតែពីរអាទិត្យប៉ុណ្ណោះ។ គាត់មិនត្រូវបានគេដាក់ខ្នោះទេ ពេលគាត់ដេកក្នុងបន្ទប់នេះ។ **សួស ធី** នាំគាត់មកដេកនៅក្នុងបន្ទប់នេះរាល់ថ្ងៃ។ ក្រោយមក គាត់ដេកនៅកន្លែងធ្វើការរបស់គាត់។ គាត់ បញ្ជាក់ថា **ប៊ូ ម៉េង** មិនបានគេឃុំក្នុងបន្ទប់នេះ ក្នុងពេលតែមួយនឹងគាត់ទេ។

*

១០. បន្ទាប់មកអ្នកចូលរួម មកជួបជុំគ្នានៅខាងក្រៅ គឺ **ខាងមុខអគារ C** [រូបថត ល.៥០]។

១០.១ សាក្សី **ប្រាក់ ខន** នៅពេលដែលត្រូវបានសួរសំណួរពាក់ព័ន្ធនឹងសេចក្តីប្រកាសកន្លងមករបស់ខ្លួនទាក់ទិននឹងការប្ចូមយកឈាមនោះ ពន្យល់ថា ការប្ចូមយកឈាមត្រូវបានគេធ្វើឡើងនៅក្នុងផ្ទះរបស់ពេទ្យដែលស្ថិតនៅខាងក្រៅ ស២១ នៅជិតផ្ទះរបស់គាត់ គឺនៅកាច់ជ្រុងផ្លូវលេខ ១១៣ និងផ្លូវលេខ ៣៣០ ស្ថិតនៅចំកន្លែងផ្ទះឈើបច្ចុប្បន្ន (ដែលសម័យនោះអត់មានផ្ទះនេះទេ) [រូបថត ល.៥១]។

១០.២ សាក្សីនានា ផ្តល់ជូននូវការបញ្ជាក់មួយចំនួនទាក់ទិននឹងការសម្លាប់៖ សាក្សី **សួស ធី** ពន្យល់ថា នៅពេលដែលអ្នកទោសត្រូវបានបញ្ជូនទៅជើងឯក រថយន្តធំ នៅរង់ចាំខាងមុខខ្លោងទ្វារ។ គាត់ ជាអ្នកកាន់បញ្ជីឈ្មោះអ្នកទោសដែលបានសួរចម្លើយរួច ហើយដែលត្រូវបញ្ជូនទៅខាងក្រៅ។ បញ្ជីនោះត្រូវបាន **ឌុច** ប្រគល់ឲ្យ **ហ៊ី** ដោយមានចំណារថា « កំទេច »។ គាត់ បានឲ្យបញ្ជីនេះទៅ **ហ៊ុយ** និង **ប៉េង** ដែលជាអ្នកទៅយកអ្នកទោសពីបន្ទប់ឃុំឃាំង។ គាត់មិនបានមកទទួលអ្នកទោស ដើម្បីយកទៅសម្លាប់នោះទេ វាគឺជាការងាររបស់អ្នកយាមផ្សេងទៀត អាស្រ័យទៅលើបញ្ជី។ គាត់ ពន្យល់

ទៀតថា ប្រសិនបើមានបញ្ហាទាក់ទងនឹងចំនួនអ្នកទោស (បាត់អ្នកទោស ឬបញ្ហាអ្វីផ្សេងទៀត) គាត់ជាអ្នកទទួលខុសត្រូវ ហើយគាត់ ត្រូវធ្វើការផ្ទៀងផ្ទាត់ជានិច្ចនៅការិយាល័យរបស់គាត់។ សាក្សី **ហ៊ឹម ហ៊ុយ** ទទួលស្គាល់ថា គាត់មាននាទីជាអ្នកទទួលអ្នកទោស នៅពេលដែលបានសួរចម្លើយហើយ ដើម្បីបញ្ជូនយកទៅសម្លាប់។ គាត់ទៅយកអ្នកទោសពីក្នុងបន្ទប់ឃុំឃាំងដោយមានជំនួយពី **ប៉េង** ដែលស្គាល់កន្លែងដាក់អ្នកទោស។ ទាក់ទិននឹងការសម្លាប់នៅក្នុងបរិវេណ ស ២១ សាក្សី **វ៉ាន់ ណាត** គូសបញ្ជាក់ថា រណ្ដៅជាច្រើនត្រូវបានគេជីកនៅក្រោយអគារ D។ សាក្សី **ប្រាក់ ខន** ពន្យល់ថា អ្នកទោសខ្លះត្រូវបានគេសម្លាប់នៅខាងត្បូង ស ២១ និងបញ្ជាក់អះអាងថា មានកន្លែងសម្រាប់សម្លាប់មួយទៀតផងដែរនៅក្រោយអគារ D ដូចដែល **វ៉ាន់ ណាត** បាននិយាយ។ គាត់ អះអាងជាថ្មីថា គាត់បានឃើញ ដែក ឬ បោះកូនក្មេងម្នាក់ (ដែលមានម្ដាយជាជនជាតិវៀតណាម) ពីជាន់ទីបីនៃអគារមួយដែលនៅខាងក្រៅនៃបរិវេណ ស ២១ បច្ចុប្បន្ន។ **សួស ធី** គូសបញ្ជាក់ថា ហ៊ី ជាអ្នកបញ្ជាឱ្យ **ប៉េង** ចាប់យកកូនក្មេងទៅបន្ទាប់ពីពួកគេមកដល់ពីរ ឬបីថ្ងៃ។ ជួនកាលកូនក្មេងត្រូវគេយកទៅដាក់ក្នុងបន្ទប់ឃុំឃាំងជាមួយឪពុកម្ដាយរបស់គេ។ គាត់មិនដឹងច្បាស់ទេថាគេបញ្ជូនកូនក្មេងទាំងអស់នោះទៅទីណា ហើយមិនដឹងថាមានរឿងអ្វីកើតឡើងចំពោះពួកគេដែរ ប៉ុន្តែគាត់គិតថា កូនក្មេងទាំងអស់នោះត្រូវបានគេយកទៅសម្លាប់។ គាត់អះអាងថា គាត់មិនដឹងថាគេដឹកជញ្ជូនកូនក្មេងទាំងនោះរបៀបណាទេ ព្រោះថាការងារនេះជារបស់ **ប៉េង** និង ហ៊ី។ **ហ៊ឹម ហ៊ុយ** ពន្យល់ថា **ប៉េង** ទទួលបន្ទុកកូនក្មេង ហើយគាត់ទទួលបន្ទុកតែលើអ្នកទោសពេញវ័យទាំងស្រីទាំងប្រុស និងគូសបញ្ជាក់បន្ថែមថា កូនក្មេងមិនត្រូវបានគេដឹកជញ្ជូនតាមឡានធំទេ។ **គង់ ផៃ** នៅតែអះអាងអំពីសេចក្ដីប្រកាសរបស់ខ្លួនកន្លងមក ដែលថា គាត់បានមានវត្តមាននៅក្នុងការសម្លាប់មួយ នៅពេលយប់។ គាត់គូសបញ្ជាក់ថា អ្នកទោសដែលគេសម្លាប់ត្រូវបានកប់នៅជិតគុកពិសេស នៅក្នុងបរិវេណ ស ២១ នាសម័យកាលដែលកើតហេតុនោះ ប៉ុន្តែនៅខាងក្រៅរបងនៃបរិវេណសព្វថ្ងៃនេះ។

*

១១. បន្ទាប់មក អ្នកចូលរួម ធ្វើដំណើរទៅកាន់ <u>អគារ A</u> ដែលនៅទីនោះមាន "បទបញ្ជាផ្ទៃក្នុង" ដែលអាចថាបានអនុវត្តនៅ ស ២១ [រូបថត ល.៥២]។

១១.១ សាក្សី **ឡៅត់ ១៦** បញ្ជាក់ថា បទបញ្ជាសួរចម្លើយទាំងនេះ មានទៅគ្រប់បន្ទប់ អាចនៅលើជញ្ជាំង ឬនៅលើក្តារខៀនពណ៌ខ្មៅ។ បទបញ្ជាទាំងនេះត្រូវបានបង្រៀននៅក្នុងវគ្គរៀនសូត្រដែលធ្វើឡើងដោយ **ឌុច** នៅក្នុងផ្ទះមួយដែលនៅជិតផ្ទះរបស់គាត់។ នៅពេលសួរចម្លើយ គេបង្ហាញបទបញ្ជាផ្ទៃក្នុងនេះដល់អ្នកទោស គេប្រាប់ឱ្យអ្នកទោស គោរពបទបញ្ជានេះ ហើយគេក៏ចាប់អនុវត្ត។

១១.២ **ជនត្រូវចោទ** ជំទាស់លើការអះអាងបែបនេះ ហើយប្រកាសថា ប្រសិនបើបទបញ្ជាទាំងនេះត្រូវបានគេបង្រៀនក្នុងវគ្គរៀនសូត្ររបស់កម្មាភិបាល ស ២១ ខ្លឹមសារនៃវិធានទាំងនេះនឹងមាននៅក្នុងកំណត់ត្រាសរសេរដៃរបស់ **មីម ណៃ, ទុយ** និង**ប៉ុន** ហើយ។ ប៉ុន្តែ គេមិនឃើញមានខ្លឹមសារនៃបទបញ្ជាទាំងនេះទេ។ គាត់បន្ថែមថា "បទបញ្ជា" ទាំងនេះ ក៏មិនមាននៅក្នុងឯកសារដែលគេដាក់ចំណងជើងជាភាសាអង់គ្លេសថា "សៀវភៅទារុណកម្ម" ដែរ។ **ឌុច** រំលឹកថា ខ្លឹមសារនៃការបង្រៀនរបស់គាត់ គឺយកចេញពីសេចក្តីណែនាំសរសេរដោយដៃ ដែលគាត់បានទទួលពី **សុន សេន**។ គាត់បានយកសេចក្តីណែនាំនោះទៅឱ្យគេវាយអង្គុលីលេខ ហើយគាត់យកទៅចែកឱ្យពួកអ្នកសួរចម្លើយ។ បើតាម **ឌុច** បទបញ្ជាទាំងនេះមិនមាននៅក្នុងឯកសារនោះទេ។ **ឡៅត់ ១៦** នៅតែប្រកាន់យកដែលខ្លួនសេចក្តីប្រកាសរបស់ខ្លួន ប៉ុន្តែគាត់គ្មានភស្តុតាងជាលាយលក្ខណ៍អក្សរបញ្ជាក់ពីអត្ថិភាពនៃបទបញ្ជានេះទេ ប៉ុន្តែ គាត់បានចងចាំបទបញ្ជាទាំងនោះ។

១១.៣ សាក្សីផ្សេងទៀត ប្រកាសថា ខ្លួនមិនអាចបានឃើញបទបញ្ជាទាំងនេះទេ។ ប៉ុន្តែ **ម៉ាន់ ណារត** ផ្តល់ជូននូវការបញ្ជាក់ដូចតទៅ ៖ នៅពេលគាត់ជាប់ឃុំឃាំង គាត់មិនបានដឹងរឿងនេះទេ ដោយសារគាត់មិនដែលធ្លាប់ត្រូវបានគេសួរចម្លើយ។ ប៉ុន្តែ នៅពេលដែលគាត់ត្រឡប់មកទួលស្លែងវិញ ក្រោយពេលរំដោះ (នៅខែវិច្ឆិកា ឬខែធ្នូ ឆ្នាំ១៩៧៩) គាត់បានឃើញបទបញ្ជាទាំងនេះដែលគេសរសេរនឹងដីសនៅលើក្តារខៀនពណ៌ខ្មៅមួយនៅក្នុងបន្ទប់មួយនៅជាន់ផ្ទាល់ដីនៃអគារ A។ គាត់បានត្រឡប់មកវិញជាលើកទីមួយនៅថ្ងៃទី ១៣ ខែមករា ឆ្នាំ១៩៧៩ ដើម្បីប្រមូលអីវ៉ាន់របស់គាត់។ នៅពេលនោះ គាត់បានចូលតែក្នុងបន្ទប់ដែលគាត់ធ្លាប់ធ្វើការប៉ុណ្ណោះ គឺមិនបានចូលក្នុងអគារ A ទេ ហើយដោយសារគាត់បានជុំក្លិនស្អុយ គាត់ក៏បានចេញពីទីនោះភ្លាមទៅ។


Extraordinary Chambers in the Courts of Cambodia National Road 4 .Chaom Chau , Dangkao Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax:023 218941
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Chaom CHau, Damgkao, Phnom Penh
Boite postale 71, Phnom Penh. Tel : Tel.+855(0)23 218914 Fax:023 218941

បន្ទាប់ពីដំណើរការនៃការសំដែងឡើងវិញបានបញ្ចប់ ជនត្រូវចោទអានសេចក្តីប្រកាសដែលខ្លួនបានរៀបចំទុកជាមុន។ ឯកសារនេះនឹងត្រូវភ្ជាប់ជាឧបសម្ព័ន្ធនៃកំណត់ហេតុនេះ (ឧបសម្ព័ន្ធ ២)។ ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី និង ប៊ូ ម៉េង មានការពេញចិត្ត បន្ទាប់ពីការអាននេះ។

អ្នកចូលរួមទាំងអស់ចាកចេញពីទីកន្លែងរៀបចំ នៅម៉ោង ១៧ និង១៥ នាទី ដោយមិនមានឧប្បត្តិហេតុណាមួយឡើយ។

ការសំដែងឡើងវិញនេះ ត្រូវបានថតជារូបភាព និងសម្លេង ហើយច្បាប់ថតចម្លងមួយច្បាប់នៃការថតរូបភាព និងសម្លេង ត្រូវបានប្រគល់ឲ្យជនត្រូវចោទ។

ច្បាប់ដើមនៃកំណត់ហេតុនេះត្រូវបានសរសេរជាភាសាខ្មែរ និង បារាំងនិងបន្ទាប់មកបកប្រែជាភាសាអង់គ្លេស។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មេសា ឆ្នាំ២០០៨

ក្រឡាបញ្ជី
Les Greffiers

LY. Chantola    ខាម ចើរ៉ល

សហចៅក្រមស៊ើបអង្កេត
Co- Investigating Judges
Co-juges d'instruction

MARCEL Lemonde    យូ ប៊ុនឡេង

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ។
Extraordinary Chambers in the Courts of Cambodia National Road 4 ,Chaom Chau , Dangkao Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax:023 218941
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Chaom CHau, Damgkao, Phnom Penh
Boite postale 71, Phnom Penh. Tel : Tel:+855(0)23 218914 Fax:023 218941